01325755

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 09 / 2016
ម៉ោង (Time/Heure): 14 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦[1]

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំប្តូរឯកសារ**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលចម្លើយតបមួយ ដែលបានដាក់នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦ ដោយមេធាវីការពារក្តី ខៀវ សំផន ("ចម្លើយតប" ឯកសារ E415/2/1) តបទៅនឹងសំណើមួយ អនុលោមតាមវិធាន ៨៧(៤) ដែលបានដាក់ដោយសហព្រះរាជអាជ្ញានៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ ("សំណើ" ឯកសារ E415/2)។ នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមួយទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨៧(៤) ដោយព្រមទទួលយកធ្វើជាឯកសារភ័ស្តុតាងនូវជំពូកទី៣ ដល់ទី ១១ នៃសៀវភៅដែលមានចំណងជើងថា *Pourquoi les Khmers Rouges ("ហេតុអ្វីបានជាមានខ្មែរក្រហម")* និពន្ធដោយលោក Henri LOCARD (2-TCE-90) ("សៀវភៅ") បោះពុម្ពនៅឆ្នាំ ២០១៦ (សេចក្តីព្រាងប្រតិចារឹកសវនាការថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦

---

[1] សំណៅឯកសារជាភាសាអង់គ្លេសត្រូវបានបញ្ជូនក្រៅផ្លូវការទៅភាគីទាំងអស់នៅថ្ងៃទី ២៧ កក្កដា ឆ្នាំ ២០១៦។

ទំព័រ ៦៦) និង បានបដិសេធដោយប្រយោលចំពោះសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យបង្គាប់ទៅសហព្រះរាជអាជ្ញាឱ្យជ្រើសរើសអត្ថបទសម្រង់ជាក់លាក់ និង ពាក់ព័ន្ធពីក្នុងសៀវភៅ។

២. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានផ្ញើអ៊ីម៉ែលមួយជូនអង្គជំនុំជម្រះសាលាដំបូង ដោយបញ្ជាក់ពីការកែតម្រូវបន្តិចបន្តួចចំពោះឯកសារ E415/2 និង ស្នើសុំឱ្យទទួលយកធ្វើជាឯកសារភស្តុតាងនូវទំព័របន្ថែមពីសៀវភៅនេះ ដែលរួមមានលេខចុងទំព័រ (endnotes) ដែលស្របទៅនឹងជំពូកទី ៣ ដល់ទី ១១ ដែលត្រូវបានទទួលយកធ្វើជាឯកសារភស្តុតាងរួចហើយ (ភ្ជាប់ជាមួយអនុស្សរណៈនេះ)។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា លេខចុងទំព័រទាំងនេះជាផ្នែកសំខាន់នៃជំពូកដែលត្រូវបានទទួលយកធ្វើជាភស្តុតាង និង សូមបញ្ជាក់ថា ទំព័រ ៣៥២-៣៦៦ នៃសៀវភៅ (លេខ ERN 01303710-01303717 ជាភាសាបារាំង) ត្រូវបានទទួលយកជាផ្នែកមួយនៃឯកសារ E3/10640។

៣. នៅក្នុងចម្លើយតប មេធាវីការពារក្តី ខៀវ សំផន ស្នើសុំការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងសៀវភៅដែលបានបោះពុម្ពឆ្នាំ ២០១៦ ដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម ("SMD")។ មេធាវីការពារក្តី ខៀវ សំផន អះអាងថា ភាគីមិនបានទទួលការជូនដំណឹងពីពេលដែលសៀវភៅសំណៅនេះត្រូវបានដាក់បញ្ចូលក្នុងឃ្លាំងផ្ទុកឯកសាររួមនេះទេ ហើយមេធាវីការពារក្តីសួរថា តើភាគីអាចប្រើសំណៅនេះនៅក្នុងសារណារបស់ពួកគេដែរ ឬ ទេ (ឯកសារ E415/2/1 កថាខណ្ឌ ១១-១២)។ ប្រសិនបើភាគីអាចធ្វើដូច្នេះបាន មេធាវីការពារក្តី ខៀវ សំផន ស្នើសុំប្តូរអត្ថបទសម្រង់ទាំង ៥ ពីសៀវភៅបោះពុម្ពឆ្នាំ ២០១៣ ដែលត្រូវបានទទួលយកធ្វើជាឯកសារភស្តុតាងរួចហើយ ដោយដាក់ជំនួសវិញនូវអត្ថបទសម្រង់ទាំងនេះពីសៀវភៅបោះពុម្ពឆ្នាំ ២០១៦ (ឯកសារ E415/2/1 កថាខណ្ឌ ១៤, ២២)។

៤. អង្គជំនុំជម្រះសាលាដំបូងយោងទៅសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ ដែលទទួលយកអត្ថបទសម្រង់ចំនួន ៥ ដែលបានលើកយោងនៅក្នុងចម្លើយតប។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះក៏បានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះបាន "ទទួលសំណៅអេឡិចត្រូនិកនៃសៀវភៅដែលត្រូវបានកែសម្រួលលើកទីពីរដែលលោក Henri LOCARD (2-TCE-90) បានផ្តល់ជូន តាមរយៈអង្គភាពគាំពារសាក្សី និង អ្នកជំនាញ នៅថ្ងៃ

ទី ០១ ខែ កក្កដា ឆ្នាំ ២០១៦"។ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះបានដាក់សៀវភៅបោះពុម្ពឆ្នាំ ២០១៦ បញ្ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួម ដើម្បីឱ្យភាគីអាចចូលពិនិត្យមើលបាន ប្រសិនបើពួកគេ "ស្នើសុំឱ្យទទួលយកអត្ថបទសម្រង់ពាក់ព័ន្ធណាមួយជាឯកសារភ័ស្តុតាង" (ឯកសារ E406/1 កថាខណ្ឌ ១៣)។ ហេតុនេះ អង្គជំនុំជម្រះយល់ថា ភាគីបានទទួលការជូនដំណឹងអំពីសៀវភៅបោះពុម្ពឆ្នាំ ២០១៦ បានទាន់ពេលវេលាហើយ។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា អត្ថបទសម្រង់ទាំង ៥ ដែលបានយោងនៅក្នុងចម្លើយតប មាននៅក្នុងជំពូកចំនួន ៩ នៃសៀវភៅបោះពុម្ពឆ្នាំ ២០១៦ ដែលត្រូវបានទទួលយកជាភ័ស្តុតាងរួចហើយ។ ហេតុនេះ សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំប្តូរអត្ថបទសម្រង់ទាំងនេះមិនមានសារប្រយោជន៍ទេ។

៥. អនុស្សរណៈនេះជាការឆ្លើយតបផ្លូវរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E415/2/1។